**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ/បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ/បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

## សម្រេច

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដែលបំពេញបន្ថែមអនុក្រឹត្យលេខ ៦២

អនក្រ/បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

**មាត្រា២ ៖-**

ពាក្យសព្ទលំនៅឋានដែលប្រើក្នុងអនុក្រឹត្យនេះសំដៅតែលើលំនៅឋានសម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះ។

**មាត្រា៣ ៖-**

អគ្គនាយកដ្ឋានលំនៅឋានមានភារកិច្ចជាសេនាធិការឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្នុងការងារ៖

- សិក្សាអំពីស្ថានភាពបច្ចុប្បន្ននៃលំនៅឋាន តម្រូវការលំនៅឋាន ការផ្គត់ផ្គង់លំនៅឋាននិងការរៀបចំដីសម្រាប់លំនៅឋានក្នុងពេលបច្ចុប្បន្ននិងនៅពេលអនាគត
- សហការជាមួយអង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សហគមន៍មូលដ្ឋាន សប្បុរសជនជាតិនិងអន្តរជាតិ ក្នុងការកៀរគរហិរញ្ញប្បទាននិង/ឬការសាងសង់លំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះឬការតាំងលំនៅថ្មី
- សិក្សាស្រាវជ្រាវអំពីស្តង់ដានិងបទដ្ឋានបច្ចេកទេសលំនៅឋានមានតម្លៃទាបនិងរៀបចំគម្រោងអភិវឌ្ឍលំនៅឋាន
- រៀបចំយុទ្ធសាស្ត្រ គោលនយោបាយនិងបទដ្ឋានគតិយុត្តសំដៅធានាសិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ប្រជាពលរដ្ឋ
- សហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការលើកទឹកចិត្តដល់ការវិនិយោគលំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះ
- សហការជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្នុងការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់តាមរាជធានីទីក្រុងនិងទីប្រជុំជន
- សហការជាមួយស្ថាប័នរដ្ឋនិងឯកជនដើម្បីរៀបចំបទដ្ឋានគតិយុត្តក្នុងការគ្រប់គ្រងមូលនិធិនិងគ្រប់គ្រងឥណទានសម្រាប់លំនៅឋានតាមលំដាប់ថ្នាក់
- គ្រប់គ្រងអចលនទ្រព្យដែលទទួលបានពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋ វិស័យឯកជននិងសប្បុរសជន
- ផ្សព្វផ្សាយនិងណែនាំដល់ប្រជាពលរដ្ឋអំពីវិធីនិងលទ្ធភាពដែលអាចទទួលបានលំនៅឋាននិងរៀបចំវេទិកាស្តីពីលំនៅឋាន
- ផ្តល់យោបល់លើគម្រោងស្នើសុំសាងសង់និងអភិវឌ្ឍលំនៅឋានសម្រាប់គោលដៅសង្គមកិច្ច

– តាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយនិងបទដ្ឋានគតិយុត្ត និងការអនុវត្តគម្រោងនានាពាក់ព័ន្ធនឹងការងារលំនៅឋាន

– បំពេញការងារផ្សេងៗទៀតពាក់ព័ន្ធនឹងការងារលំនៅឋាន ពិសេសកម្មវិធីលំនៅឋានសង្គមកិច្ច។

**មាត្រា៤ .-**

អគ្គនាយកដ្ឋានលំនៅឋានមាននាយកដ្ឋានចំណុះចំនួន ៣ ដូចខាងក្រោម៖

– នាយកដ្ឋានបទប្បញ្ញត្តិ ផែនការនិងទំនាក់ទំនងសហប្រតិបត្តិការការងារលំនៅឋាន

– នាយកដ្ឋានបច្ចេកទេសនិងអភិវឌ្ឍលំនៅឋាន

– នាយកដ្ឋានមូលនិធិនិងឥណទានលំនៅឋាន

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធាន០១រូបនិងមានអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់។

អង្គការលេខរបស់អគ្គនាយកដ្ឋានលំនៅឋានជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៥ .-**

នាយកដ្ឋានបទប្បញ្ញត្តិ ផែនការនិងទំនាក់ទំនងសហប្រតិបត្តិការការងារលំនៅឋានមានតួនាទីនិងភារកិច្ចដូចតទៅ៖

– រៀបចំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន

– សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំបទដ្ឋានគតិយុត្តដើម្បីធានាសិទ្ធិទទួលបានលំនៅឋានសមរម្យរបស់ប្រជាពលរដ្ឋ

– សិក្សាទីផ្សារលំនៅឋាន

– ចងក្រងនិងធ្វើបច្ចុប្បន្នកម្មទិន្នន័យអំពីតម្រូវការលំនៅឋាននិងបញ្ចូលកម្មវិធីលំនៅឋានទៅក្នុងផែនការប្រើប្រាស់ដី

– សហការជាមួយភាគីពាក់ព័ន្ធដើម្បីប្រមូលនិងចងក្រងទិន្នន័យនិងព័ត៌មានស្តីពីលំនៅឋានរបស់សហគមន៍ប្រជាពលរដ្ឋក្រីក្រនិងសំណង់បណ្តោះអាសន្ននៅតាមរាជធានី ទីក្រុងនិងទីប្រជុំជនដើម្បីស្វែងរកដំណោះស្រាយ

– ផ្សព្វផ្សាយនិងណែនាំដល់ប្រជាពលរដ្ឋអំពីវិធីនិងលទ្ធភាពអាចទទួលបានលំនៅឋានសមរម្យ តាមរយៈក្របខ័ណ្ឌហិរញ្ញប្បទានផ្សេងៗក្នុងការសាងសង់ ជួសជុល កែលម្អនិងថែទាំលំនៅឋាន

– រៀបចំការបណ្តុះបណ្តាល សិក្ខាសាលានិងការផ្លាស់ប្តូរបទពិសោធពាក់ព័ន្ធនឹងការងារលំនៅឋាននិងវេទិកាស្តីពីលំនៅឋាន

– ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍជាតិនិងអន្តរជាតិ សង្គមស៊ីវិលនិងវិស័យឯកជនក្នុងការរៀបចំគម្រោងអភិវឌ្ឍដីសម្រាប់សាងសង់លំនៅឋាន គម្រោងសាងសង់លំនៅឋានមានតម្លៃទាប គម្រោងអភិវឌ្ឍសហគមន៍និងគម្រោងស្ថាបនាមូលនិធិសង្គមសម្រាប់លំនៅឋាន

- រៀបចំនិងលើកសំណើផែនការថវិកាបស់នាយកដ្ឋាន
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំបទដ្ឋានគតិយុត្តដើម្បីលើកទឹកចិត្តដល់ការវិនិយោគលំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះ
- តាមដាននិងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ គោលនយោបាយនិងបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលំនៅឋាននិងគម្រោងអភិវឌ្ឍនានាតាមលំដាប់ថ្នាក់
- បូកសរុបនិងធ្វើរបាយការណ៍ការងារនិងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានលំនៅឋានប្រគល់ឲ្យ។

**មាត្រា៦ .-**

នាយកដ្ឋានបច្ចេកទេសនិងអភិវឌ្ឍលំនៅឋានមានតួនាទីនិងភារកិច្ចដូចតទៅ៖

- ស្រាវជ្រាវនិងចងក្រងឯកសារពាក់ព័ន្ធនឹងសម្ភារៈ បរិក្ខារសំណង់ក្នុងស្រុកនិងបរិក្ខារនាំចូលសម្រាប់លំនៅឋានមានតម្លៃទាបនិងផ្សព្វផ្សាយគំរូបច្ចេកទេសលំនៅឋានមានតម្លៃទាប
- សិក្សាស្រាវជ្រាវអំពីស្តង់ដានិងបទដ្ឋានបច្ចេកទេសលំនៅឋានមានតម្លៃទាប
- សិក្សាគម្រោងនិងគាំទ្របច្ចេកទេសសាងសង់លំនៅឋានមានតម្លៃទាបសម្រាប់ប្រជាពលរដ្ឋក្រីក្រឬការផ្លាស់ទីតាំងថ្មី
- សិក្សាប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងលំនៅឋាននិងប្រភេទលំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះ
- ចូលរួមរៀបចំហេដ្ឋារចនាសម្ព័ន្ធសម្រាប់លំនៅឋានក្នុងគម្រោងអភិវឌ្ឍនិងកម្មវិធីកែលម្អលំនៅឋាន
- ចូលរួមក្នុងដំណើរការនៃការដោះស្រាយលំនៅឋានដែលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍនានាឬពីគ្រោះមហន្តរាយផ្សេងៗ
- ផ្តល់យោបល់លើគម្រោងអភិវឌ្ឍលំនៅឋានសម្រាប់គោលដៅសង្គមកិច្ចនិងគ្រប់គ្រងគម្រោងប្លង់ស្ថាបត្យកម្មនិងនគរូបនីយកម្មដែលទទួលបានការសម្រេចពីសមត្ថកិច្ចជំនាញ
- ចូលរួមសម្របសម្រួលនិងសហការជាមួយស្ថាប័នពាក់ព័ន្ធជាតិនិងអន្តរជាតិ ក្នុងការសិក្សាគម្រោងប្លង់លំនៅឋានសម្រាប់ប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាបនិងក្រុមជនងាយរងគ្រោះ
- តាមដាននិងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍលំនៅឋានមានតម្លៃទាបនិងបូកសរុបការងាររបស់នាយកដ្ឋាន
- រៀបចំនិងលើកសំណើផែនការថវិការបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកដ្ឋានលំនៅឋានប្រគល់ឲ្យ។

**មាត្រា៧ .-**

នាយកដ្ឋានមូលនិធិនិងឥណទានលំនៅឋាន មានតួនាទីនិងភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវបទដ្ឋានហិរញ្ញវត្ថុសម្រាប់គាំទ្រដល់ការងារលំនៅឋាន
- ស្រាវជ្រាវទីផ្សារសេវាហិរញ្ញវត្ថុនិងមូលនិធិលំនៅឋាន
- សហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុរដ្ឋនិងឯកជនដើម្បីអនុវត្តការងារមូលនិធិនិងឥណទានលំនៅឋានផ្សេងទៀត
- កៀរគរហិរញ្ញប្បទានអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងប្រភពហិរញ្ញប្បទានជាតិសម្រាប់ការងារលំនៅឋាននិងការតាំងលំនៅថ្មី
- គ្រប់គ្រងអចលនទ្រព្យដែលទទួលបានពីកិច្ចសហប្រតិបត្តិការរវាងរដ្ឋ វិស័យឯកជន និងសប្បុរសជន
- បង្កើតនិងគ្រប់គ្រងមូលនិធិនិងឥណទានលំនៅឋាន
- តាមដានការអនុវត្តគម្រោងសាងសង់និងកែលម្អលំនៅឋានដែលប្រើហិរញ្ញប្បទានសម្រាប់លំនៅឋាន
- លើកគម្រោងថវិកាប្រចាំឆ្នាំនិងគ្រប់គ្រងការអនុវត្តថវិការបស់អគ្គនាយកដ្ឋាន
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈនិងធ្វើបញ្ជីសារពើភណ្ឌរបស់អគ្គនាយកដ្ឋាន
- ធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំខែ ប្រចាំត្រីមាសនិងប្រចាំឆ្នាំស្តីពីការប្រើប្រាស់ឥណទានដែលបានមកពីប្រភពហិរញ្ញប្បទានលំនៅឋានរបស់អគ្គនាយកដ្ឋាន
- បូកសរុបនិងធ្វើរបាយការណ៍ការងាររបស់នាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកដ្ឋានលំនៅឋានប្រគល់ឲ្យ។

**មាត្រា៨ .-**

នាយកដ្ឋាននីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

**មាត្រា៩ .-**

នៅតាមមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ត្រូវបង្កើតឱ្យមានការិយាល័យលំនៅឋាន។

នៅតាមការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតឱ្យមានផ្នែកលំនៅឋានដើម្បីទទួលការងារលំនៅឋាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យលំនៅឋាននិងផ្នែកលំនៅឋានត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

**មាត្រា១០ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១១ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែកញ្ញា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

**សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៨៤៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤**
**ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អង្គការលេខរបស់អគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

